ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៦៥
ចុះថ្ងៃទី១១-០៧-០៥
សាលដីកាលេខ៖៤២
ចុះថ្ងៃទី១០-០៥-២០០៦

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១- ឯកឧត្តម ... ប្រធាន
២- លោក ... ចៅក្រម
៣-លោក ... ចៅក្រម
៤- លោក ... ចៅក្រម
៥- លោក ... ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី
លោក ...
តំណាងមហាអយ្យការ
ឯកឧត្តម...អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ៦៤(ឃ) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល។

***ពីបទៈ*** ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិក្រូចឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១២ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនជាប់ចោទឈ្មោះ **ចខ** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៣៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រាំងពោធិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ មុខរបរធ្វើស្រែទីលំនៅសព្វថ្ងៃភូមិក្រូ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ។ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន០៥នាក់។ ចាប់ខ្លួនថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៩ ឃុំខ្លួនថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៩ ។

-មានមេធាវីការពារលោក...

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ទប** ភេទប្រុសអាយុ៤៥ឆ្នាំ ជាតិខ្មែរមុខរបរធ្វើចម្ការ ទីលំនៅសព្វថ្ងៃភូមិត្រាំងពោធិ ឃុំពត់សរ ស្រុកបាទីខេត្តតាកែវ។

-កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ វេលាម៉ោង ៨.៣០ នាទីយប់ លោក **បសផត** មេឃុំពត់សរ ស្រុកបាទី បានចាត់កម្លាំងកងជីវពលឃុំចំនួន០៥នាក់ ចុះទៅបង្ក្រាបបទល្មើសឆក់ត្រី ក្នុងនោះមាន **ចខ** ចូលរួមផងដែរ។ ក្នុងពេលបង្ក្រាបនៅបឹងហង់ខ្លា ក៏ជួបអ្នកឆក់ត្រី ហើយពួកនោះបាននាំគ្នារត់ ឈ្មោះ **ចខ** ឃើញដូច្នេះក៏បាញ់ទៅលើ និងស្រែកឱ្យពួកគេឈប់ តែពួកគេនៅតែរត់ដដែល ខណៈសេនាជនទាំង០៥នាក់ ក៏បានដេញតាមហើយបានផ្ទុះអាវុធព្រមគ្នា ហើយបណ្តាលឱ្យជនរងគ្រោះឈ្មោះ **បស** ដួលស្លាប់នៅនឹងកន្លែងតែម្តង។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តតាកែវថាៈ ចោទប្រកាន់លើឈ្មោះ **ចខ** ភេទប្រុសអាយុ៣៧ឆ្នាំ ជាតិខ្មែរ របររក

ស៊ីជាកងជីវពល ឃុំពត់សរ ស្រុកបាទី ទីលំនៅសព្វថ្ងៃភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ឪពុកឈ្មោះ...ម្ដាយឈ្មោះ... ប្រពន្ធឈ្មោះ...មានកូន០៥នាក់។ ទោសពីមុនគ្មាន។ពីបទមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅបឹងហង់ខ្លា ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ ដែលបានសម្រេចៈ

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ **ចខ** ភេទប្រុសអាយុ៣៧ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ដាក់ពន្ធនាគារកំណត់០៨ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួន។

ពីបទៈ សម្លាប់មនុស្សដោយចេតនា ប្រព្រឹត្តនៅភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១២ខែមិថុនា ឆ្នាំ១៩៩៩ តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-បង្គាប់ឱ្យឈ្មោះ **ចខ** សងជំងឺចិត្តជាប្រាក់ចំនួន៥.000.000រៀល (ប្រាំលានរៀល) ឱ្យទៅឈ្មោះ **ទប** ជាដើមបណ្ដឹងរដ្ឋប្បវេណី ឯការទាមទារលើសពីនេះត្រូវលើកចោល។ បើរឹងទទឹងមិនព្រមបង់សងទេនោះអនុញ្ញាតឱ្យដាក់គុកបង្ខំលើរូបកាយ ដើម្បីទាមទារធនទណ្ឌខាងលើ តាមមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបកាយ។

៣-វត្ថុតាងមានអាវុធAK មួយដើមលេខ៩១០៧ បង់មួយ សម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។ អាគុយម៉ាកតូក្យូ៤០អំពែ មួយគ្រឿង,ខ្សែភ្លើង២ម៉ែត្រ, ធុងដាក់ត្រីមួយ សម្រេចរឹបអូស និងបំផ្លាញចោល។ សាលក្រមនេះប្រកាសជា

សាធារណៈចំពោះមុខជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។បើក ផ្លូវប្តឹងឧទ្ធរណ៍កំណត់៦០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះ **ចខ** ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៥ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវលើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៤(ឃ) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច។

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះ **ចខ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ ទុកជាបានការ ដោយគ្រាន់តែបន្ថយរយៈពេលផ្តន្ទាទោស **ចខ** ពី០៨ឆ្នាំ មកត្រឹម០៦ឆ្នាំ (ប្រាំមួយឆ្នាំ) វិញតាមមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងបង្គាប់ឱ្យអាជ្ញាធរឃុំពត់សរសងជំងឺចិត្តជាប្រាក់ចំនួន ៥លានរៀល(ប្រាំលាន)ឱ្យទៅឈ្មោះ **ទប** ជាដើមបណ្តឹង។ចំណុចផ្សេងទៀតរក្សាទុកជាបានការដដែល។

៣-សាលដីកានេះ ជនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ មេធាវីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញ បណ្ដឹងសាទុក្ខលេខ១១ ចុះថ្ងៃទី១៧ខែមករាឆ្នាំ២០០៥ របស់អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្ដឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៦៤(យ) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចតម្រូវ ឱ្យអាជ្ញាធរឃុំពត់សរ ទទួលខុសត្រូវខាងរដ្ឋប្បវេណី ដោយពុំទាន់ចាត់របៀបបញ្ចូលជាភាគីក្នុងសំណុំរឿង។

-បានឃើញសារណា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ជាម្ចាស់បណ្ដឹងសាទុក្ខ ធ្វើឡើងតាមកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៥ របស់ឈ្មោះ **ចខ** ជាចុងបណ្ដឹងសាទុក្ខ ធ្វើឡើងតាមកំណត់ច្បាប់។

-បានស្ដាប់ចៅក្រមរបាយការណ៍អានរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា:មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ **ចខ** ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានស្ដាប់ក្រឡាបញ្ជី អានសារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

-បានស្ដាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ **ចខ** ជាចុងបណ្ដឹងសាទុក្ខ នៅពេលជំនុំជម្រះថា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ វេលាម៉ោង៨យប់រូបខ្ញុំបាទ ដែលជាកងជីវពលឃុំពត់សរ ក្រោយពេល ដែលបានទទួលដំណឹងថា មានជនមួយក្រុមយកប្រដាប់ឆក់ត្រីខុសច្បាប់ទៅឆក់ រូបខ្ញុំបាទក៏បាន

ទៅមើលហើយស្រែកថាកុំធ្វើដូច្នេះតែពួកគេមិនស្តាប់ខ្ញុំបាទក៏បាញ់២គ្រាប់ឡើង ទៅលើ ដើម្បីឱ្យអ្នកទាំងអស់ឈប់រត់ត្រី និងយកសម្ភារៈដើម្បីបំផ្លាញចោល ខ្ញុំបាទសូមបញ្ជាក់ថា នៅពេលបាញ់មិនមែនតែរូបខ្ញុំម្នាក់ទេជាអ្នកបាញ់ គឺមានឈ្មោះ **ឈឈ** ក៏បានបាញ់ដែរ តែគេមិនត្រូវចាប់ខ្លួន។ ខ្ញុំបាទសូមសំណូមពរឱ្យឃុំពត់សរ ចេញសងជំនួសខ្ញុំបាទ ហើយសូមរក្សាសាលដីកាបស់សាលាឧទ្ធរណ៍លេខ៦៤(ឃ) នៅដដែល។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី **ទប** ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជម្រះថា: ខ្ញុំបាទគ្មានយោបល់អ្វីទេ សូមឯកឧត្តមប្រធានមេត្តាសម្រេច។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក......ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **ចខ** ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជម្រះថា៖ សូមឯកឧត្តមមេត្តាសម្រេចតម្កល់សាលាដីកាព្រហ្មទណ្ឌលេខ៦៤(ឃ) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ នៅដដែល។

-បានស្តាប់សេចក្តីសន្និដ្ឋាន បន្ថែមរបស់តំណាងមហាអយ្យការអមតុលាការ កំពូលនៅពេលជំនុំជម្រះថា គ្មានយោបល់អ្វីបន្ថែមទៀតទេ សូមក្រុមប្រឹក្សាមេត្តាសម្រេច។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាក្នុងបណ្តឹងសាទុក្ខ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចម្លើយរបស់ឈ្មោះ **ចខ** និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

# តុលាការកំពូល

-យល់ឃើញថា ពាក្យបណ្ដឹងសាទុក្ខលេខ១១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៩ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដី។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនរងគ្រោះពិតជាបានទទួលមរណៈភាពដោយការបាញ់របស់កងជីវពល តាមការចាត់តាំងរបស់អាជ្ញាធរ ឃុំពត់សរ ប្រាកដមែន។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យអាជ្ញាធរឃុំពត់សរសងជំងឺចិត្តទៅដើមបណ្ដឹងរដ្ឋប្បវេណី ជាការត្រឹមត្រូវហើយ ប៉ុន្តែការមិនបានបញ្ចូលអាជ្ញាធរឃុំពត់សរនេះមកជាភាគីមួយនៃរឿងក្ដីនេះ ជាការពុំត្រឹមត្រូវទេ ដែលគប្បីទុកជាមោឃៈចំណុចនេះ ដើម្បីការពារសិទ្ធតវ៉ារបស់អាជ្ញាធរ ឃុំពត់សរ និងជាប្រយោជន៍ច្បាប់។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦៤(ឃ) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ ប៉ុន្តែគតិច្បាប់មានការខុសឆ្គងត្រង់ ពុំបានបញ្ចូលអ្នកទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណីមកជាភាគីនៃរឿងក្ដី។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី

១-ទទួលបណ្ដឹងសាទុក្ខលេខ១១ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៥ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៦៤(ឃ) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងត្រង់ចំណុចបង្គាប់ឱ្យអាជ្ញាធរឃុំពត់សរ សងជំងឺចិត្តជាប្រាក់ទៅឈ្មោះ **ទប** ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវទុកជាមោឃៈ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០០៥ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះឡើងវិញត្រង់ចំណុច បង្គាប់ឱ្យអាជ្ញាធរ ឃុំពត់សរ សងជំងឺចិត្តជាប្រាក់ ទៅឈ្មោះ **ទប** ជាដើមបណ្ដឹងរដ្ឋប្បវេណី។

៤-សាលដីកានេះ ប្រកាសសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦។